
© UNICEF Cambodia/2016/Antoine Raab

## ឯកសារស្តីពី

# ការអនុវត្តកិច្ចការពារកុមារ

## គន្លឹះទី១

ការអនុវត្តគោលការណ៍ "**ឧត្តមប្រយោជន៍កុមារ**" និង "**ការមិនបង្កការឈឺចាប់**" ដើម្បីគាំទ្រការធ្វើសមាហរណកម្មកុមារពីមណ្ឌលថែទាំកុមារទៅគ្រួសារ និងសហគមន៍វិញ

## គោលបំណង

គោលបំណងរបស់ឯកសារនេះ គឺដើម្បីពន្យល់អត្ថន័យនៃពាក្យថា "**ឧត្តមប្រយោជន៍កុមារ**" និង "**ការមិនបង្កការឈឺចាប់**" ដើម្បីពង្រឹងចំណេះដឹងរបស់បុគ្គលិកសង្គម អ្នកគ្រប់គ្រងករណី មន្ត្រីរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (មន្ទីរ ស.អ.យ) គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំសង្កាត់ (គ.ក.ន.ក)។ នេះគឺជាផ្នែកមួយនៃការអនុវត្តផែនការសកម្មភាពជាតិ និងផែនការប្រតិបត្តិការថ្នាក់ខេត្ត ដើម្បីកែលម្អការថែទាំកុមារ ក្នុងគោលដៅបញ្ជូនកុមារចំនួន ៣០% ពីមណ្ឌលថែទាំកុមារឱ្យត្រឡប់ទៅរួមរស់ជាមួយគ្រួសារវិញដោយសុវត្ថិភាពត្រឹមចុងឆ្នាំ ២០១៨។

# ឧត្តមប្រយោជន៍ និងការមិនបង្កការឈឺចាប់

គោលការណ៍ឧត្តមប្រយោជន៍របស់កុមារ គឺជាគោលការណ៍មូលដ្ឋានគ្រឹះមួយនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ (អ.ស.ក)។ ឧត្តមប្រយោជន៍របស់កុមារចាំបាច់ត្រូវតែជាការពិចារណាចម្បងនៅក្នុងការសម្រេចចិត្តដែលអាចជះឥទ្ធិពលលើកុមារ។ ឧត្តមប្រយោជន៍របស់កុមារត្រូវបានធានានៅក្នុងមាត្រា ៣(១) នៃ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារដែលបានចែងថា៖ "... នៅក្នុងវិធានការទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជន ឬសាធារណៈទទួលភារៈខាងសុខុមាលភាពសង្គម ឬដោយតុលាការ ឬអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ឧត្តមប្រយោជន៍កុមារត្រូវតែយកចិត្តទុកដាក់ជាចម្បង"។ ការអនុវត្តឱ្យបានពេញលេញនូវទស្សនទានស្តីពីឧត្តមប្រយោជន៍របស់កុមារ ទាមទារឱ្យមានការអនុវត្តយុទ្ធវិធីផ្អែកលើសិទ្ធិ និងការចូលរួមពីសំណាក់គ្រប់តួអង្គទាំងអស់ ដើម្បីធានានូវគុណតម្លៃ ផ្នែកចិត្តសាស្ត្រ ផ្នែកសីលធម៌ និងស្មារតីរបស់កុមារឱ្យបានគ្រប់ជ្រុងជ្រោយ និងដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់កុមារ។ ទស្សនទានស្តីពីឧត្តមប្រយោជន៍របស់កុមារមានបំណងធានាឱ្យកុមារទទួលបានសិទ្ធិទាំងអស់ ដែលត្រូវបានទទួលស្គាល់ក្នុង អ.ស.ក យ៉ាងពេញលេញ និងប្រកបដោយប្រសិទ្ធភាព។ មនុស្សពេញវ័យទាំងអស់ត្រូវគិតថា តើការសម្រេចចិត្តរបស់ពួកគេនឹងជះឥទ្ធិពលលើកុមារយ៉ាងណាខ្លះ ហើយត្រូវធ្វើអ្វីដែលល្អបំផុតសម្រាប់កុមារ។ ទស្សនទាននេះមានលក្ខណៈស្មុគស្មាញ ហើយចាំបាច់ត្រូវកំណត់ខ្លឹមសាររបស់វាយោងតាមករណីជាក់ស្តែងនីមួយៗ។ គោលការណ៍នេះត្រូវបានសម្រួល និងកំណត់និយមន័យយោងទៅតាមស្ថានភាពជាក់លាក់របស់កុមារ ដោយត្រូវពិចារណាទៅលើបរិបទ ស្ថានភាព និងសេចក្តីត្រូវការរបស់ពួកគេ។

ការមិនបង្កការឈឺចាប់មានន័យថា សុខុមាលភាពរបស់កុមារមិនត្រូវបានកាត់បន្ថយ ឬបោះបង់ក្រោមកាលៈទេសៈណាមួយឡើយ។ គោលការណ៍នេះមានន័យថា "ត្រូវការពារកុមារពីគ្រោះថ្នាក់"។ ហេតុនេះ ការបង្រួបបង្រួមគ្រួសារ និងសមាហរណកម្មកុមារចាំបាច់ត្រូវធានាសុខុមាលភាព និងការអភិវឌ្ឍរបស់កុមារ។ គោលការណ៍នេះ រួមមានទាំងការបំពេញសេចក្តីត្រូវការផ្នែកសម្ភារៈ ការអប់រំ និងសុខភាពផ្លូវចិត្ត ក៏ដូចជាសេចក្តីត្រូវការក្តីស្រឡាញ់ និងសុវត្ថិភាពផងដែរ។

ឧត្តមប្រយោជន៍របស់កុមារ និងការមិនបង្កការឈឺចាប់ គឺជាគោលការណ៍ស្នូលនៃការងារកិច្ចការពារកុមារ  និងកម្មវិធីផ្អែកលើសិទ្ធិមនុស្ស ដោយហេតុថាកុមារមានសិទ្ធិរស់នៅក្នុងជីវិតមានសេរីភាព សេចក្តីថ្លៃថ្នូរសមភាព និងសុវត្ថិភាព។ កុមារមានសិទ្ធិពិសេស ដោយសារពួកគេមានវ័យក្មេង និងងាយរងគ្រោះ។ កុមារមិនអាចរស់រាន និងសម្រេចសក្តានុពលពេញលេញរបស់ខ្លួនឡើយ ប្រសិនបើពុំមានការជួយជ្រោមជ្រែង និងកិច្ចសហការពីមនុស្សពេញវ័យទេនោះ។

គោលការណ៍ការមិនបង្កការឈឺចាប់ និងឧត្តមប្រយោជន៍របស់កុមារ មានអន្តរទំនាក់ទំនងគ្នាទៅវិញទៅមក។ គោលការណ៍ឧត្តមប្រយោជន៍របស់កុមារ ក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគោលការណ៍ដទៃទៀត ដូចជា សិទ្ធិទទួលបានការមិនរើសអើង សិទ្ធិមានជីវិត សិទ្ធិរស់រាន និងអភិវឌ្ឍន៍ និងសិទ្ធិត្រូវបានគេស្តាប់មតិយោបល់។

# គោលការណ៍ឧត្តមប្រយោជន៍របស់កុមារ និងគោលការណ៍មិនបង្កការឈឺចាប់ អនុវត្តចំពោះការថែរក្សាគ្រួសារ

នៅក្នុងបរិបទនៃការថែរក្សាគ្រួសារ និងការរក្សាទំនាក់ទំនង យើងឃើញថា គ្រួសារគឺជាឯកតាមូលដ្ឋានគ្រឹះរបស់សង្គម និងជាបរិយាកាសធម្មជាតិសម្រាប់ការចម្រើនវ័យ និងសុខុមាលភាពរបស់សមាជិកគ្រួសារ ជាពិសេស គឺកុមារ។ ការទប់ស្កាត់ការបំបែកកុមារពីគ្រួសារ និងការថែរក្សាគ្រួសារ គឺជាសមាសធាតុដ៏សំខាន់នៃប្រព័ន្ធកិច្ចការពារកុមារគ្រប់ទីកន្លែងទាំងអស់។ ការដកហូតកុមារចេញពីការថែទាំរបស់គ្រួសារ ក៏គួរតែជាជម្រើសចុងក្រោយ និងបណ្តោះអាសន្នប៉ុណ្ណោះ ប្រសិនបើគ្រួសាររបស់គេបង្ករការគំរាមកំហែង និងគ្រោះថ្នាក់ដល់កុមារ។ ការសម្រេចចិត្តដកហូតកុមារចេញពីគ្រួសារ គួរត្រូវបានពិនិត្យឡើងវិញជាប្រចាំ ហើយការបញ្ជូនកុមារត្រឡប់ទៅក្រោមការថែទាំរបស់ឪពុកម្តាយវិញ លុះត្រាតែមូលហេតុដើម ដែលធ្វើឱ្យមានការដកហូតកុមារត្រូវបានដោះស្រាយ ហើយធ្វើឡើងដើម្បីជាឧត្តមប្រយោជន៍របស់កុមារ។

ប្រសិនបើចាំបាច់ត្រូវយកកុមារទៅដាក់ក្រោមការថែទាំរបស់មណ្ឌលថែទាំកុមារ ហើយត្រូវកំណត់រកទីតាំងកន្លែងថែទាំកុមារនោះឱ្យបានក្បែរផ្ទះរបស់កុមារបំផុតតាមដែលអាចធ្វើបាន ដើម្បីជួយសម្រួលឱ្យអាចបន្តទំនាក់ទំនង និងលទ្ធភាពធ្វើសមាហរណកម្មទៅកាន់គ្រួសារវិញ និងដើម្បីកាត់បន្ថយការរំខានដល់ការអប់រំ ព្រមទាំងជីវិតផ្នែកវប្បធម៌ និងផ្នែកសង្គមរបស់កុមារឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។

# គន្លឹះសម្រាប់ការធ្វើសមាហរណកម្ម

នៅក្នុងដំណើរការធ្វើសមាហរណកម្មទាំងមូល បុគ្គលិកសង្គមត្រូវធានាយ៉ាងណាឱ្យកុមារ និងគ្រួសារបានយល់ និងផ្តល់ការព្រមព្រៀងចំពោះយុទ្ធសាស្ត្រការធ្វើសមាហរណកម្ម និងការគាំទ្រ។ ជាការសំខាន់ដែលត្រូវបញ្ជាក់ឱ្យច្បាស់អំពីសេវានានាដែលនឹងត្រូវផ្តល់ឱ្យ ព្រមទាំងបទបញ្ញត្តិច្បាប់ដែលគ្របដណ្តប់លើសេវាទាំងនេះ (ឧ. គោលការណ៍រក្សាការសម្ងាត់)។ កុមារ និងគ្រួសារ/អាណាព្យាបាល គួរបានទទួលព័ត៌មានអំពីអត្ថប្រយោជន៍ និងហានិភ័យ ហើយត្រូវផ្តល់ការសន្យាអនុវត្តតាម។ ជាការចាំបាច់ណាស់ដែលត្រូវទទួលបានការព្រមព្រៀងផ្អែកលើព័ត៌មានត្រឹមត្រូវ។ ចំណុចនេះ មានន័យថា បុគ្គលិកសង្គមត្រូវពិគ្រោះយោបល់ជាមួយកុមារស្តីពីអ្វីដែលពួកគេចង់បាន។ ត្រូវគោរពទស្សនៈយល់ឃើញរបស់កុមារ។

នៅក្នុងដំណាក់កាលត្រៀមធ្វើសមាហរណកម្មទាំងមូល ជាការចាំបាច់ណាស់ដែលត្រូវពិចារណាអំពីបរិយាកាសដែលកុមារកំពុងរស់នៅ។ បុគ្គលិកសង្គមចាំបាច់ត្រូវជ្រើសរើសយកការថែទាំក្នុងទម្រង់សមស្របជាងគេបំផុតផ្អែកលើការប៉ាន់ប្រមាណនីមួយៗ។ កុមារគួរបន្តស្ថិតនៅក្នុងការថែទាំជំនួសយូរបំផុតតាមការចាំបាច់ ដើម្បីត្រៀមខ្លួនពួកគេធ្វើសមាហរណកម្ម ឬដើម្បីរកគ្រួសារអចិន្ត្រៃយ៍ថ្មីដល់ពួកគេក្នុងករណីជម្រើសទីមួយពុំអាចធ្វើបាន។ ទោះយ៉ាងណាក្តី ជាការសំខាន់ដែលត្រូវធានាថា កុមារា និងកុមារី ពុំជាប់ក្នុងការថែទាំជំនួសរយៈពេលយូរ ព្រោះការថែទាំជំនួសគ្រាន់តែជាដំណោះស្រាយបណ្តោះអាសន្នប៉ុណ្ណោះ ហើយពុំផ្តល់លំនៅអចិន្ត្រៃយ៍ដែលកុមារត្រូវការ ដើម្បីស្ថាបនាមានអារម្មណ៍ថាមានសុវត្ថិភាព និងជាចំណែកមួយនៃគ្រួសារនោះឡើយ។

បុគ្គលិកសង្គមចាំបាច់ត្រូវធានាឱ្យបានថា កុមារត្រូវបានបញ្ជូនទៅក្នុងសាលារៀន ហើយបន្តសិក្សាសម្រាប់ការអភិវឌ្ឍអនាគតរបស់ខ្លួន។ ការផ្ទេរការសិក្សា គួរត្រូវបានធ្វើឡើងឱ្យចប់សព្វគ្រប់មុនពេលបង្រួបបង្រួមជាមួយគ្រួសារ ឬសាច់ញាតិវិញ។ កុមារគួរត្រូវបានទទួលការឧបត្ថម្ភសម្ភារសិក្សា សៀវភៅ និងឯកសារអប់រំ ក៏ដូចជាឯកសណ្ឋានសិស្សតាមការចាំបាច់។

បុគ្គលិកសង្គមត្រូវប្រាកដថា កុមារនឹងត្រូវបានទទួលអាហារគ្រប់គ្រាន់ ជម្រកសមស្រប និងការថែទាំវេជ្ជសាស្ត្រគ្រប់គ្រាន់។ ចំណុចនេះមានន័យថា កុមារម្នាក់នឹងមិនត្រូវបានបញ្ជូនទៅរួមរស់ជាមួយឪពុកម្តាយ ឬសាច់ញាតិដែលខ្វះមធ្យោបាយរស់រាន ឬជាជនអនាថា និងខ្វះលទ្ធភាពទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រឡើយ។ គ្រួសារប្រភេទនេះគួរទទួលបានការគាំទ្រ ដើម្បីឱ្យពួកគេអាចផ្តល់ការថែទាំដូចដែលបានពោលខាងដើមដល់កុមារ។

បុគ្គលិកសង្គមត្រូវធានាឱ្យបានថា គ្រួសារមានលទ្ធភាពទទួលបានប្រាក់ចំណូល/ធនធានគ្រប់គ្រាន់ ដើម្បីរក្សាចំណងគ្រួសារ និងឱ្យកុមាររស់នៅរួមជាមួយគ្នា។ ការគាំទ្រក្នុងការបង្កើតចំណូល និងការគាំទ្រផ្នែកជីវភាពរស់នៅសម្រាប់គ្រួសារជួបការខ្វះខាត គួរត្រូវបានផ្តល់ជូនដល់ឪពុកម្តាយ និងសាច់ញាតិនៅមុន និងក្រោយពេលបង្រួបបង្រួមកុមារ។

នៅក្នុងដំណើរការនៃការវាយតម្លៃគ្រួសារ ការបញ្ជូនកុមារទៅរួមរស់ជាមួយគ្រួសារ និងការធ្វើសមាហរណកម្ម បុគ្គលិកសង្គមចាំបាច់ត្រូវពិចារណាលើសុវត្ថិភាព និងសិទ្ធិរបស់កុមារឱ្យពួកគេបានទទួលការការពារពីគ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សាផ្លូវកាយ ឬផ្លូវចិត្ត គ្រោះថ្នាក់ ឬការរំលោភបំពាន ការបៀតបៀនផ្លូវភេទ ការដាក់សម្ពាធពីមិត្តភក្តិ ការសម្លុត ការប្រព្រឹត្តបន្ទាបបន្ថោក ការកេងប្រវ័ញ្ចន៍ផ្លូវភេទ ផ្នែកសេដ្ឋកិច្ច និងការកេងប្រវ័ញ្ចដទៃទៀត គ្រឿងញៀន ឬពលកម្មដោយបង្ខំ។ បុគ្គលិកសង្គមគួរធានាយ៉ាងណាឱ្យកុមារបានទទួលសុវត្ថិភាព និងមានការមើលថែ។ ចំណុចនេះមានន័យថា កុមារនឹងមិនត្រូវបានបញ្ជូនឱ្យទៅរួមរស់ជាមួយគ្រួសារ ឬយកទៅដាក់ឱ្យរស់នៅជាមួយឪពុកម្តាយ ឬសាច់ញាតិជាជនប្រមឹក ប្រើហិង្សា និងមានលក្ខណៈរំលោភបំពានឡើយ។ ការរំលោភបំពាន ការមិនអើពើ អំពើហិង្សា និងការកេងប្រវ័ញ្ចន៍នៅក្នុងគ្រួសារ គឺជាហេតុផលភាគច្រើនបំផុតដែលធ្វើឱ្យកុមារចាកចេញពីផ្ទះ។ ដោយមានកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំង គេអាចដោះស្រាយបញ្ហាទាំងអស់នេះបាននៅក្នុងគ្រួសារដែលអាចមានលទ្ធភាព ដើម្បីជៀសវាងការបំបែកកុមារចេញពីគ្រួសារជាថ្មីវិញម្តងទៀត។

ដើម្បីធានាថា គោលការណ៍ការមិនបង្កគ្រោះថ្នាក់ត្រូវបានយកទៅអនុវត្តយ៉ាងម៉ឺងម៉ាត់ និងធានាបានថាកុមារដែលត្រូវធ្វើសមាហរណកម្មចេញពីមណ្ឌល ទទួលបានការគាំទ្រប្រកបដោយគុណភាពល្អ កិច្ចការពារ និងការថែទាំ បានត្រឹមត្រូវ និងមានគោលបំណងច្បាស់លាស់នៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត បុគ្គលិកសង្គមគួរអនុវត្តគ្រប់ជំហានទាំងអស់នៃការគ្រប់គ្រងករណី (សូមមើលផែនការប្រតិបត្តិការ)។

បុគ្គលិកសង្គមចាំបាច់ត្រូវព្យាយាមយ៉ាងណាជៀសវាងកុំបង្កបញ្ហានៅពេលធ្វើការគ្រប់គ្រងករណី និងការងារសមាហរកម្ម។ ការការពារល្អបំផុតដែលបុគ្គលិកសង្គមអាចផ្តល់ជូនកុមារបានគឺត្រូវមានការយល់ដឹងអំពីហានិភ័យនិងសក្តានុពល  ហើយអនុវត្តការវិនិច្ឆ័យ និងការប្រុងប្រយ័ត្នឱ្យបានល្អ។ នៅពេលកំពុងអនុវត្តការគ្រប់គ្រងករណី និងការធ្វើសមាហរកម្មកុមារចេញពីមណ្ឌល បុគ្គលិកសង្គម និងអ្នកគ្រប់គ្រងករណី ត្រូវទទួលខុសត្រូវក្នុងការឆ្លើយតបតាមគោលដៅកម្មវិធីនៃការបង្រួបបង្រួមកុមារ ហើយស្របពេលជាមួយគ្នានោះត្រូវជៀសវាងហានិភ័យជាសក្តានុពលដែលកុមារអាចជួបប្រទះក្រោយពេលបង្រួបបង្រួមគ្រួសារ។

# ការយកគោលការណ៍ឧត្តមប្រយោជន៍របស់កុមារ និងគោលការណ៍មិនបង្កការឈឺចាប់ទៅអនុវត្តក្នុងអំឡុងពេលធ្វើសមាហរណកម្ម

ដើម្បីធានាសុខុមាលភាពរបស់កុមារទាំងអស់នៅគ្រប់មណ្ឌលថែទាំកុមារ និងការធ្វើសមាហរណកម្មកុមារដែលមិនចាំបាច់រស់នៅក្នុងមណ្ឌលថែទាំ  ពោលគឺ កុមារទាំងឡាយណាដែលនៅមានឪពុក ឬម្ដាយយ៉ាងហោចណាស់ម្នាក់នៅរស់ ឬមានសមាជិកគ្រួសារដទៃទៀតដែលអាចផ្ដល់ការថែទាំដល់ពួកគេបាន ការបង្រួបបង្រួមគ្រួសារគឺជាជម្រើសដ៏ល្អបំផុត។ ក្នុងករណីដែលគ្រួសារកំណើតរបស់កុមារមិនអាចផ្ដល់ការថែទាំគ្រប់គ្រាន់ដល់កុមារ បើទោះបីជាមានការគាំទ្រសមស្របហើយក្ដី ឬបោះបង់ ឬមិនចង់ទទួលយកកុមារ រដ្ឋត្រូវទទួលខុសត្រូវក្នុងការការពារសិទ្ធិរបស់កុមារ និងធានាឱ្យមានការថែទាំជំនួសសមស្របតាមរយៈអាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ច និងអង្គការសង្គមស៊ីវិលដែលបានទទួលសិទ្ធិត្រឹមត្រូវ។ ការថែទាំជំនួសអាចធ្វើឡើងក្នុងទម្រង់ដូចជា ការថែទាំដោយសាច់ញាតិ ឬការថែទាំដោយឪពុកម្ដាយធម៌ ការរស់នៅដោយឯករាជ្យក្រោមការត្រួតពិនិត្យ ឬ ការថែទាំក្នុងមណ្ឌល។ ជម្រើសការថែទាំតាមគ្រួសារនិងសហគមន៍ គួរតែជាអាទិភាពដំបូង ។ ការថែទាំតាមមណ្ឌល គួរត្រូវបានប្រើប្រាស់លើមូលដ្ឋានបណ្ដោះអាសន្ន និងជាជម្រើសចុងក្រោយបំផុត។ ក្នុងករណីបានពិនិត្យអស់លទ្ធភាពលើគ្រប់ទម្រង់នៃការថែទាំជំនួស គប្បីពិចារណាលើការសុំកូនក្នុងប្រទេសផងដែរ។

ក្នុងអំឡុងពេលដំណើរការបង្រួបបង្រួមគ្រួសារ មន្ត្រីសង្គមកិច្ចចាំបាច់ត្រូវវាយតម្លៃលើស្ថានភាពដែលធានានូវឧត្តមប្រយោជន៍របស់កុមារ និងឱកាសដើម្បីឱ្យកុមារមានលទ្ធភាពទទួលបានការថែទាំសុខភាព ការអប់រំប្រកបដោយគុណភាពរួមទាំងការអប់រំកុមារតូច ការអប់រំក្រៅប្រព័ន្ធ ឬការអប់រំក្នុងប្រព័ន្ធ ក៏ដូចជាសកម្មភាពពាក់ព័ន្ធដទៃទៀត ព្រមទាំងឱកាសដើម្បីចូលរួម និងសម្រេចបានមហិច្ឆិតាប្រាថ្នាចង់បានរបស់ខ្លួន។ បុគ្គលិកសង្គមគួរវាយតម្លៃឱ្យបានត្រឹមត្រូវថាតើ កុមារត្រូវបានបញ្ជូនមករួមរស់ជាមួយគ្រួសារវិញក្នុងបរិយាកាសរស់នៅរបស់គ្រួសារដែលមានសន្តិសុខ និងមានស្ថេរភាព។ មានន័យថា បុគ្គលិកសង្គមមិនត្រូវបង្រួបបង្រួមកុមារជាមួយគ្រួសារដែលមានអំពើហិង្សា ដោយមិនទាន់បានដោះស្រាយបញ្ហា ហើយមិនប្រាកដថាកុមារនិងអាចរស់នៅដោយមានសុវត្ថិភាពនោះទេ។

រាល់ដំណើរការធ្វើសមាហរណកម្មទាំងអស់ត្រូវមានគោលបំណងផ្ដល់ប្រយោជន៍ដល់កុមារ។ ដំណើរការទាំងនេះមិនត្រូវបង្កគ្រោះថ្នាក់ដល់កុមារ ឬធ្វើឱ្យប៉ះពាល់ដល់ជីវិតសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្ត ឬសុខុមាលភាពរបស់កុមារឡើយ។ បុគ្គលិកសង្គមត្រូវធ្វើការវាយតម្លៃហានិភ័យឱ្យបានត្រឹមត្រូវ ដើម្បីកំណត់រកប្រភពគ្រោះថ្នាក់ដែលអាចបង្កឡើងដោយការធ្វើសមាហរណកម្មនេះ ព្រមទាំងកំណត់រកជំហាននានា ដើម្បីកាត់បន្ថយហានិភ័យចំពោះកុមារ និងគ្រួសារ។

## ឯកសារយោង

អនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩

អនុសាសន៍រួមរបស់គណកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិលេខ ១៤ ស្ដីពីសិទ្ធិឧត្តមប្រយោជន៍កុមារត្រូវតែយកចិត្តទុកដាក់ជាអាទិភាព ឆ្នាំ២០១៣

សេចក្ដីណែនាំរបស់មហាសន្និបាតអង្គការសហប្រជាជាតិស្ដីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០០៦

បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជំនួសចំពោះកុមាររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ ២០០៦

ផែនការពង្រឹងការថែទាំកុមារនិងសមាហរណកម្មកុមារចំនួន ៣០ ភាគរយពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាពពីឆ្នាំ២០១៦ ទៅឆ្នាំ២០១៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០១៧

*ឯកសារនេះត្រូវបានរៀបរៀងដោយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងមូលនិធិសហប្រជាជាតិដើម្បីកុមារ។*

unicef
for every child